# របាយការណ៍

## ស្តីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែ កុម្ភៈ ឆ្នាំ២០១៤

## និងទិសដៅការងារ ខែ មីនា ឆ្នាំ២០១៤

(ពីថ្ងៃទី ០១/០២/២០១៤ ដល់ ថ្ងៃទី ២៥/០២/២០១៤)

ខែកុម្ភៈឆ្នាំ២០១៤នេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តតាមយុទ្ធសាស្ត្រពហុវិស័យនៃផែនការជាតិ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (២០១៣-២០១៥) និងទិសដៅការងារដែលបានដាក់ចេញកាលពីខែមករាឆ្នាំ២០១៤ កន្លងទៅ ដើម្បីរួមចំណែកអនុវត្ត "គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ទទួលបានលទ្ធផលដូចខាងក្រោម :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

តាមរបាយការណ៍របស់អគ្គស្នងការដ្ឋាននគរបាលជាតិ, កងរាជអាវុធហត្ថលើផ្ទៃប្រទេស, គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ដែលបានរាយការណ៍ពីលទ្ធផលនៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន បានបង្ហាញថា សកម្មភាពចរាចរ ជួញដូរ និងប្រើប្រាស់គ្រឿងញៀន បានកើតមាននៅរាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, កណ្តាល, តាកែវ, កំពង់ចាម, សៀមរាប, ស្ទឹងត្រែង, រតនគិរី, បាត់ដំបង, កោះកុង, បន្ទាយមានជ័យ និង ខេត្តក្រចេះ ។ កត់សំគាល់ ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបានកើតឡើងនៅក្នុងដែនសមត្ថកិច្ចរបស់បណ្តារាជធានី-ខេត្ត ខាងលើ គឺមានបទល្មើសគ្រឿងញៀនធំៗ ចំនួន ៥ ករណី ។ ក្នុងនោះមាន ៣ ករណី ត្រូវបានមន្ទីរប្រឆាំងគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សហការជាមួយស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ, ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ, អង្គភាពគយ-រដ្ឋាករប្រចាំច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ធ្វើការបង្ក្រាបទាន់ពេលវេលា ព្រមទាំងចាប់យកគ្រឿងញៀនប្រភេទ មេតំហ្វេតាមីនក្រាមម្សៅ អ៊ិចស្តាស៊ី កូកាអ៊ីន សរុបជាង ៦ គីឡូក្រាម ។ ចំណែក កងរាជអាវុធហត្ថខេត្តបាត់ដំបង និងខេត្តស្ទឹងត្រែង បង្ក្រាបបាន ២ ករណី ព្រមទាំងចាប់យកគ្រឿងញៀនប្រភេទ មេតំហ្វេតាមីន ក្រាមម្សៅ ប្រមាណជិត ២ គីឡូក្រាម ។

ជាមួយគ្នានេះដែរ យើងក៏បានប្រទះឃើញមានលេចឡើងនូវបាតុភាពនៃការធ្វើអាជីវកម្ម និងការប្រើប្រាស់ (ជក់) ផលិតផលដែលមានឈ្មោះថា SISHA និង E-Cigarette ដោយចំហ បើទោះបីផលិតផលនេះ មិនមានផ្ទុកសារធាតុដែលមានចែងក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនក៏ពិតមែន ប៉ុន្តែវាមានផ្ទុកនូវសារធាតុ នីកូទីនសំយោគ ក្នុងកម្រិតខ្ពស់ ដែលបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពធ្ងន់ធ្ងរជាងបារី ហើយឧបករណ៍ តិរិយាបថ និងរបៀបប្រើប្រាស់ មានលក្ខណៈងាយស្រួល និងមានលទ្ធភាពងាយជំរុញ និងលើកទឹកចិត្តឱ្យមានចំណង់ប្រើប្រាស់យ៉ាងខ្លាំង ហើយអាចឈានទៅរកការប្រើប្រាស់ប្រភេទគ្រឿងញៀនខុសច្បាប់ផ្សេងៗទៀត ដោយលាយជាមួយនឹងផលិតផលខាងលើ ។

# II. អំពីការងារដឹកនាំ និង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

## ១. អំពីការងារដឹកនាំ

### ១.១. ការដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ

ថ្នាក់ដឹកនាំនៃស្ថាប័នកំពូលរបស់ជាតិ ជាពិសេស សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានបន្តណែនាំ និងដឹកនាំបញ្ហាលើការងារត្រួតពិនិត្យគ្រឿងញៀន ជាគោលការណ៍សំខាន់ៗ រួមមាន :

- បានអនុញ្ញាតឱ្យអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៣ និងលើកទិសដៅការងារ ឆ្នាំ២០១៤ ។
- បានណែនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឱ្យចាត់វិធានការជាបន្ទាន់ដើម្បីទប់ស្កាត់ការនាំចូលនូវផលិតផល SISHA និង E-Cigarette ព្រមទាំងធ្វើការរឹបអូសនូវផលិតផលទាំងនោះ ដែលបាននាំចូលកន្លងមក និងធ្វើការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ ដល់ស្រទាប់យុវវ័យ ។

### ១.២. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តណែនាំ និងដឹកនាំបញ្ហាលើការងារជាគោលសំខាន់ៗ រួមមាន :

**ក- អំពីគោលការណ៍ណែនាំ និងការដឹកនាំបញ្ជា** ឯកឧត្តមបានណែនាំឱ្យអគ្គលេខាធិការ :

- រៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួងសមាជិក អ.ជ.ប.គ.ញ ដើម្បីពិនិត្យលើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៣ និងទិសដៅការងារ ឆ្នាំ២០១៤ ។
- ចូលរួមសន្និសីទស្តីពី ការអនុវត្តច្បាប់គ្រឿងញៀននៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក លើកទី១៩ ។
- ចូលរួមកិច្ចប្រជុំក្រុមការងារអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន របស់ អាស៊ាន ។
- ចូលរួមកិច្ចប្រជុំ ស្តីពីលទ្ធផលការងាររបស់គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ។
- រៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៣ និងលើកទិសដៅការងារ ឆ្នាំ២០១៤ របស់ អ.ជ.ប.គ.ញ ។
- ចុះពិនិត្យទីតាំង សម្ភារៈការិយាល័យទំនាក់ទំនងព្រំដែន (BLO) និងជំរុញការិយាល័យទំនាក់ទំនងព្រំដែន (BLO) ឱ្យមានដំណើរការ ។

- អនុញ្ញាតជូន ឯកឧត្តម អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដឹកនាំប្រតិភូទៅចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរបស់អង្គការសហប្រជាជាតិ នៅទីក្រុងវីយែន ប្រទេសអូទ្រីស ។
- បន្តកិច្ចសហការជាមួយក្រសួងសុខាភិបាល ដើម្បីជំរុញការងារព្យាបាលដោយផ្អែកលើសហគមន៍នៅរាជធានីភ្នំពេញឱ្យបានឆាប់រហ័ស ។

**ខ- អំពីលិខិតបទដ្ឋានគតិយុត្តិ** ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានណែនាំឱ្យអគ្គលេខាធិការ :

- ពិនិត្យ និងពិភាក្សាជាមួយក្រសួងយុត្តិធម៌, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រុមអ្នកច្បាប់ ឱ្យបានល្អិតល្អន់លើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន មុននឹងដាក់សេចក្តីព្រាងនេះ ជូនអង្គប្រជុំអន្តរក្រសួង សមាជិក អ.ជ.ប.គ.ញ ពិនិត្យ និងសម្រេច ។
- សហការជាមួយបណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីកែសម្រួលខ្លឹមសារឯកសារបណ្តុះបណ្តាលសម្រាប់មន្ត្រីអនុវត្តន៍ស្តីពី យុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព ក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន ។

## ២. *អំពីលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន*

ផ្តើមចេញពីគោលការណ៍ដឹកនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ក៏ដូចជាផែនការអនុវត្តទិសដៅការងារដែលបានដាក់ចេញកាលពី **ខែមករា ឆ្នាំ២០១៤** កន្លងទៅ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបន្តអនុវត្តវិធានការពហុវិស័យទទួលបានលទ្ធផលដូចខាងក្រោម :

### ២.១. *ការកាត់បន្ថយតម្រូវការគ្រឿងញៀន*

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ក៏ដូចជាក្រសួង-ស្ថាប័នជាសមាជិក និងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំង គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានបន្តយកចិត្តទុកដាក់អនុវត្តការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយក្នុងកម្មវិធី ប្រចាំថ្ងៃ-សប្តាហ៍-ខែ, ការអប់រំតាមសហគមន៍ និងការបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមសហគមន៍ ទទួលបានលទ្ធផល **ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី១** ។

**ដោយឡែក អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ** បាន :

- ផ្តល់កិច្ចសម្ភាសន៍ស្តីពី ការប្រើប្រាស់ និងការជួញដូរគ្រឿងញៀន ដល់និស្សិតចំនួន ៤ រូប នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ដែលត្រូវបំពេញលក្ខខណ្ឌក្នុងមុខវិជ្ជាសិក្សារបស់ខ្លួន ។
- ចូលរួមផ្តល់បទសម្ភាសន៍ក្នុងកម្មវិធី សភាអ៊ីនធឺណេត នៃស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ស្តីពីសកម្មភាព និងលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៣ របស់ អ.ជ.ប.គ.ញ កាលពីថ្ងៃទី ២៦/០២/២០១៤ ។
- សហការជាមួយ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្តគោលដៅ, អគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ជាតិ, វិទ្យុ-ទូរទស្សន៍បាយ័ន, វិទ្យុ-ទូរទស្សន៍ម៉ាយធីវី, ក្រុមហ៊ុនហង្សមាស, ក្រុមហ៊ុនខារ៉ាបាវ, ក្រុមហ៊ុនកូកាកូឡា

និងក្រុមហ៊ុនទូរស័ព្ទចល័ត Smart mobile បញ្ច្រាបខ្លឹមសារអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈកម្មវិធីប្រគំតន្ត្រីស្រុកស្រែ និងតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុន ដែលធ្វើនៅខេត្តព្រះសីហនុ, កំពង់ស្ពឺ, បន្ទាយមានជ័យ, បាត់ដំបង, កំពង់ឆ្នាំង, កំពត, កែប, តាកែវ, កណ្ដាល, ស្វាយរៀង និងខេត្តព្រៃវែង មានមហាជនចូលរួមទស្សនាសរុប **២០៩.000** នាក់ ។

**ជារួម** សកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀននៅតាមសហគមន៍ និងបណ្តុះបណ្តាលជនបង្គោលនៅតាមសហគមន៍ ដែលបានអនុវត្តដោយក្រសួង-ស្ថាប័ន ព្រមទាំងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ចំនួន *៤* គឺ ខេត្តកំពង់ចាម, ក្រចេះ, ស្វាយរៀង និង បាត់ដំបង នៅក្នុងខែកុម្ភៈឆ្នាំ២០១៤ នេះ មានមហាជនចូលរួម ***២៤១.៥៩៧ នាក់*** លើ **៣៦៧.៣១៤** នាក់ នៃខែមករា ឆ្នាំ២០១៤ **ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី១** ។

### ***២.២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន***

ក្នុងខែកុម្ភៈនេះ មន្ត្រីអនុវត្តន៍ច្បាប់បានបន្តយកចិត្តទុកដាក់ចូលរួមសហការគ្នាបង្ក្រាបបទល្មើសគ្រឿងញៀន គ្រប់ប្រភេទ សំដៅកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម :

### ***ក. ការងារបង្ក្រាបបទល្មើសគ្រឿងញៀន***

- **បទល្មើសគ្រឿងញៀន** ដែលបង្ក្រាបបាន សរុបរួម **៥៥** ករណី លើ ៧៥ ករណី នៃខែមករា ឆ្នាំ២០១៤
- **ជនសង្ស័យ** ពាក់ព័ន្ធបទល្មើសគ្រឿងញៀន ដែលបានឃាត់ខ្លួន **១៣៦** នាក់ លើ ១៦៧ នាក់ នៃខែមករា ឆ្នាំ២០១៤

  ក្នុងចំនួនបទល្មើសគ្រឿងញៀនទាំង ៥៥ ករណី និង ជនសង្ស័យទាំង ១៣៦ នាក់ ខាងលើនេះ គឺ :

  ✓ **បទល្មើសគ្រឿងញៀនដែលបង្ក្រាបដោយ កងកម្លាំងនគរបាលជាតិ** មាន ៣៧ ករណី, ជនសង្ស័យ ១០៦ នាក់

  ✓ **បទល្មើសគ្រឿងញៀនដែលបង្ក្រាបដោយ កងរាជអាវុធហត្ថ** មាន ១៨ ករណី, ជនសង្ស័យ ៣០ នាក់

- ក្នុងចំនួនជនសង្ស័យពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដែលបានឃាត់ខ្លួនទាំង **១៣៦** នាក់ ខាងលើ មានប្រុស ១១៨ នាក់ ស្រី ១៨ នាក់ ក្នុងនោះ មាន 0៦ សញ្ជាតិ គឺ **ខ្មែរ** ១២៨ នាក់ ( ស្រី ១៧ នាក់), **ឡាវ** 0១ នាក់ ( ប្រុស), **ថៃ** 0១ នាក់ ( ប្រុស), **ចិន** 0៣ នាក់ ( ប្រុស), **នីហ្សេរីយ៉ា** 0២ នាក់ ( ប្រុស), **ហ្វីលីពីន** 0១ នាក់ ( ស្រី) ត្រូវសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ។

- **វត្ថុតាងគ្រឿងញៀនចាប់យក** រួមមាន មេតំហ្វេតាមីនគ្រាប់ WY ២២៩,៥0 ក្រាម, មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៣.២0៥,៩៥ ក្រាម, អ៊ិចស្តាស៊ី ៣.១១៨,៤៦ ក្រាម, កូកាអ៊ីន ២.៥១៣ ក្រាម ។
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ចាប់យក រួមមាន** : ម៉ូតូ ១៨ គ្រឿង, រថយន្ត ៣ គ្រឿង, ប្រាក់រៀល ១0៥.៧00 រៀល, ប្រាក់អាមេរិក ៨៦២ ដុល្លារ, ប្រាក់បាត ១៤0 បាត **ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី២** ។

**ដោយឡែក** ជនសង្ស័យចាប់តាមដីកា មាន ៣ ដីកា = មនុស្ស ៣ នាក់ ( ប្រុស) ជនជាតិខ្មែរ ។

### ***ខ. ការត្រួតពិនិត្យ និងការគ្រប់គ្រងសារធាតុគីមីផ្សំ***

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងសុខាភិបាល និងក្រុម-ប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ, វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលនៅក្នុង **ខែកុម្ភៈ ឆ្នាំ២០១៤** នេះ មានដូចខាងក្រោម :

- សារធាតុគីមី សរុប ៧.៧៨៨.៣១៥ គ.ក្រ
- វត្ថុធាតុដើម និងឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទចំនួន ៥៣៨ ក្រាម, ១.២៧៧ មិល្លីក្រាម **ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២** ។

### ***គ. ការងារកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន***

មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តន៍ច្បាប់នានា និងតុលាការរាជធានី-ខេត្ត នៅក្នុងខែកុម្ភៈឆ្នាំ២០១៤នេះ សរុបចំនួន ៧៥ ករណី = ១០២ សំណាក ក្នុងនោះ សំណាក **អវិជ្ជមានសារធាតុញៀនទាំង** ១៩ សំណាក និង **សំណាកវិជ្ជមាន** ៨៣ សំណាក គឺ ៖

-មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៥៨ សំណាក = ៦៩ % -មេតំហ្វេតាមីនគ្រាប់ (WY) ២៣ សំណាក = ១៩ %

-ហេរ៉ូអ៊ីន ១ សំណាក = ១ % -កញ្ឆា ០១ សំណាក = ១ %

**ដោយឡែក** គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ នៃក្រសួងការពារជាតិ បានរៀបចំកិច្ចប្រជុំពេញអង្គស្តីពីលទ្ធផលការងាររបស់គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ឆ្នាំ២០១០-២០១៣ កាលពីថ្ងៃទី១៣/០២/២០១៤ ។

## ***២.៣. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម***

- បានសហការជាមួយក្រសួងសុខាភិបាល អង្គការFHI360 រៀបចំកិច្ចប្រជុំនៅខេត្តកំពង់ចាម ដើម្បីផ្សព្វផ្សាយនិងចាប់ផ្តើមអនុវត្តគម្រោងកម្មវិធីបង្ការមេរោគអេដស៍និងគ្រឿងញៀននៅកម្ពុជា កាលពីថ្ងៃទី១១/០២/២០១៤ ដែលមានសមាសភាពពាក់ព័ន្ធចូលរួម សរុប ៦០ នាក់ ។
- បានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ លើសេចក្តីព្រាង "កម្មវិធីសិក្សាបំណិនជីវិត ស្តីពីការអប់រំសុខភាពនៅកន្លែងសិក្សា" កាលពីថ្ងៃទី ១៧/០២/២០១៤ តាមការអញ្ជើញ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានសមាសភាពចូល រួម **១៣** នាក់ ដើម្បីស្តាប់បាន និងពិនិត្យលទ្ធភាពក្នុងការបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន ។
- បានអនុញ្ញាតឱ្យអង្គការ "កសាង" អនុវត្តកម្មវិធី ម្តុល/ស៊ីរ៉ាំង សាកល្បងរយៈពេល ១ ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី ០១ ខែមីនា ឆ្នាំ២០១៤ ដល់ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៥ ។

### ២.៤. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

**ការងារនេះ អគ្គលេខាធិការដ្ឋាន** បាន :

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ លើកទី២ ដើម្បីកែសម្រួលឯកសារបណ្តុះបណ្តាលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ស្តីពី យុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព ក្នុងការកាត់បន្ថយគ្រោះថ្នាក់ ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន កាលពីថ្ងៃទី១១-១៣/០២/២០១៤ ។
- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ធ្វើជាគ្រូបង្គោល ផ្តល់បទបង្ហាញស្តីពីការអនុវត្តគម្រោង PATROL នៅកម្ពុជា ក្នុងសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការអង្កេតនិងត្រួតពិនិត្យសារធាតុបំផ្លាញស្រទាប់អូហ្សូន ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ២៦-២៧/០២/២០១៤ ដែលមានមន្ត្រីមកពីក្រសួង-ស្ថាប័ន ពាក់ព័ន្ធចូលរួមសរុប ៣០ នាក់ ។
- បានចាត់តាំងក្រុមការងាររបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចុះទៅការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៃច្រកចាំយាម (ខេត្តកោះកុង), ច្រកព្រំ (ខេត្តប៉ៃលិន), ច្រកដូង (ខេត្តបាត់ដំបង), ច្រកប៉ោយប៉ែត (ខេត្តបន្ទាយមានជ័យ), ច្រកជ្រៃធំ (ខេត្តកណ្តាល) ពីថ្ងៃទី០៨/០១ ដល់ ០២/០២/២០១៤ ដើម្បីពិនិត្យទីតាំង សម្ភារៈ និងត្រៀមរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលបច្ចេកទេសត្រួតពិនិត្យគ្រឿងញៀនដោយកុំព្យូទ័រ (CBT) ។

### ២.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានខិតខំបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ តាមរយៈយន្តការ ទ្វេភាគី ត្រីភាគី និងពហុភាគី ជាមួយបណ្តាប្រទេសជិតខាង ប្រទេសក្នុងអនុតំបន់ តំបន់ និង អន្តរជាតិ មានដូចខាងក្រោម :

**ការងារក្នុងប្រទេស**

- បានទទួលរៀបចំកិច្ចប្រជុំ ទ្វេភាគី កម្ពុជា-ថៃ លើកទី៨ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន កាលពីថ្ងៃទី០៤-០៧ នៅខេត្តកែប ដើម្បីពិនិត្យលទ្ធផលនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន នាពេលកន្លងទៅ និងពិភាក្សាលើវិធានការចាំបាច់នានា ដែលត្រូវបន្តអនុវត្តក្នុងឆ្នាំ២០១៤ ។
- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ១ រូប ចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលចម្រុះ នៃតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម លើកទី៩ និង កិច្ចប្រជុំពាក់ព័ន្ធ កាលពីថ្ងៃទី២៧/០២ ដល់ ថ្ងៃទី០៤/០៣/២០១៤ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ។

**ការងារក្រៅប្រទេស**

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ១ រូប ទៅចូលរួមក្នុងសន្និសីទ ស្តីពីការអនុវត្តច្បាប់គ្រឿងញៀន នៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក លើកទី១៩ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន កាលពីថ្ងៃទី១៨-២០/០២/២០១៤ ។
- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ១ រូប ទៅចូលរួមកិច្ចប្រជុំក្រុមការងារអនុវត្តន៍ច្បាប់ត្រួតពិនិត្យគ្រឿង

ញៀនរបស់អាស៊ាន (ASOD Working Group on Law Enforcement) លើកទី១ នៅសាធារណរដ្ឋសហភាពមីយ៉ានម៉ា កាលពីថ្ងៃទី១០-១១/០២/២០១៤ ។

- បានទំនាក់ទំនង និងសម្របសម្រួលជាមួយភាគី វៀតណាម និង ភាគីថៃ ដើម្បីរៀបចំបញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់កម្ពុជា ចំនួនពីរក្រុម (១ក្រុម មាន ២០ រូប) ទៅចូលរួមក្នុង :
  - សិក្ខាសាលាស្តីពី កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀនតាមបណ្តោយព្រំដែន កម្ពុជា-ថៃ នៅខេត្តចាន់ថាបូរី ប្រទេសថៃ ។
  - វគ្គបណ្តុះបណ្តាលស្តីពី ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់គ្រឿងញៀន នៅទីក្រុងហូជីមិញ នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ។
- បានទំនាក់ទំនងជាមួយភាគី វៀតណាម និង ឡាវ ដើម្បីរៀបចំដំណើរទស្សនកិច្ចជូនប្រតិភូជាន់ខ្ពស់ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

***ការងារផ្សេងៗ :***

ដើម្បីបំពេញឱ្យការងារត្រួតពិនិត្យគ្រឿងញៀនពហុវិស័យ អគ្គលេខាធិការដ្ឋាន បានអនុវត្តការងារមួយចំនួនបន្ថែមទៀតជាអាទិ៍ :

- កិច្ចប្រជុំក្រុមការងារអន្តរក្រសួងសមាជិក អ.ជ.ប.គ.ញ ដើម្បីពិនិត្យលើសេចក្តីព្រាងរបាយការណ៍ស្តីពី លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៣ និងលើកទិសដៅការងារ ឆ្នាំ២០១៤ របស់ អ.ជ.ប.គ.ញ (២៤/០២/២០១៤) ។
- កិច្ចប្រជុំឆ្លងសេចក្តីព្រាងរបាយការណ៍សន្និបាត បូកសរុបការងារសម្រាប់ឆ្នាំ២០១៣ និងលើកទិសដៅការងារឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ (០៦/០២/២០១៤) ។
- កិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី១០/០២/២០១៤ ។

# III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែមីនា ឆ្នាំ២០១៤

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តអនុវត្តទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

## ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១. សម្របសម្រួលជាមួយក្រសួងយុត្តិធម៌ ដើម្បីផ្តល់កិច្ចសម្ភាសន៍តាមកម្មវិធី សភាអ៊ីនធឺណេត នៃស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ស្តីពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (២៦/៣/២០១៤) ។

១.២. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត វិស័យឯកជន

ដើម្បី បញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនទៅក្នុងការប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្ម នៅតាមរាជធានី-ខេត្ត គោល ដៅនានា ។

១.៣. បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ និងវិស័យឯកជន ដើម្បីជំរុញការផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និង ឯកជន ។

១.៤. បន្តជំរុញការងារបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាម ក្រសួង-ស្ថាប័ន រោងចក្រ-សហគ្រាស និងនៅតាមសហគមន៍ ។

## ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

២.១. សហការសម្របសម្រួលជាមួយមន្ទីរប្រឆាំងគ្រឿងញៀន, ការិយាល័យប្រឆាំងគ្រឿងញៀន រាជធានី-ខេត្ត និង កងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្នុងការស្រាវជ្រាវរកខ្សែរយៈទាក់ទងដែលនៅសេសសល់ពាក់ព័ន្ធនឹងករណីធំៗដែលបង្ក្រាបបានកន្លងមក ។

២.២. សហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីចាត់វិធានការបន្សាបសារធាតុគីមី ដែលបានឃាត់ទុកកាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១២ នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ ចំនួន ១៨.៩០០ គ.ក្រ ។

២.៣. បន្តកិច្ចសហប្រតិបត្តិការផ្តល់ព័ត៌មានគ្រឿងញៀនឱ្យគ្នាទៅវិញទៅមកជាមួយប្រទេសជិតខាង ។

២.៤. ជំរុញកិច្ចប្រជុំឱ្យបានទៀងទាត់ រវាងបណ្តាខេត្តនិងខេត្តជាប់ព្រំដែន កម្ពុជា-ថៃ / កម្ពុជា-ឡាវ / កម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ។

២.៥. បន្តសហការសម្របសម្រួលជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីរៀបចំសេចក្តីព្រាងប្រកាសស្តីពី ការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ។

## ៣. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម

៣.១. ត្រៀមដឹកនាំប្រតិភូ ចូលជួបសំដែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

៣.២. សហការជាមួយក្រសួងសុខាភិបាល ដើម្បីរៀបចំឯកសារដែលពាក់ព័ន្ធនឹងការបង្ការ ការថែទាំ និងព្យាបាលបន្ត និងស្តារនីតិសម្បទាចិត្ត-សង្គម ចំពោះអ្នកប្រើប្រាស់គ្រឿងញៀន និងអ្នកចាក់គ្រឿងញៀន ។

៣.៣. កែសម្រួលសេចក្តីព្រាង "គោលនយោបាយ និងគោលការណ៍ណែនាំស្តីពីការអនុវត្តកម្មវិធី ម្ហូល/ស៊ីរ៉ាំង នៅកម្ពុជា និង គោលការណ៍ណែនាំបន្ថែមសម្រាប់គាំទ្រមន្ត្រីអនុវត្តច្បាប់ចំពោះកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

៣.៤. បន្តការផ្តល់សេវាថែទាំ ព្យាបាល និងផ្តល់របបឧបត្ថម្ភដល់អ្នកញៀនគ្រឿងញៀន ដែលកំពុងសម្រាកព្យាបាលនៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ។

៣.៥. បន្តពង្រឹងសមត្ថភាពការងារព្យាបាលដោយផ្អែកលើសហគមន៍ តាមប្រព័ន្ធសុខាភិបាលដែលមានស្រាប់ ( មន្ទីរពេទ្យបង្អែក-មណ្ឌលសុខភាព) នៅទូទាំងប្រទេស ដោយយកបទពិសោធន៍តាមខេត្តបន្ទាយមានជ័យ និងខិតខំសហការ

សម្របសម្រួលលើការងារព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមប៉ុស្តិ៍សុខភាពពន្ធនាគារ ។

៣.៦. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ជំរុញការអនុវត្តកម្មវិធី មេតាដូន នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ។

# ៤. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

៤.១. ចាត់បញ្ជូនមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងសម្របសម្រួលជូនមន្ត្រីអនុវត្តន៍ច្បាប់ ចំនួន ២០ រូប ទៅទទួលវគ្គបណ្តុះបណ្តាលស្តីពី ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់គ្រឿងញៀន ចាប់ពីថ្ងៃទី២៤ ដល់ ថ្ងៃទី ២៨/៣/២០១៤ នៅទីក្រុងហូជីមិញ សាធារណរដ្ឋសង្គមនិយមវៀតណាម ។

៤.២. ចាត់បញ្ជូនមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងសម្របសម្រួលជូនមន្ត្រីអនុវត្តន៍ច្បាប់ ចំនួន ២០ រូប ទៅចូលរួមសិក្ខាសាលាស្តីពី កិច្ចសហការអនុវត្តច្បាប់គ្រឿងញៀនតាមព្រំដែន កម្ពុជា-ថៃ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៦-២៨/០៣/២០១៤ នៅខេត្តចាន់ថាបូរី ប្រទេសថៃ ។

៤.៣. ដឹកនាំប្រតិភូរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចូលជួបសំដែងការគួរសម និងពិភាក្សាការងារជាមួយ ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការនគរបាលជាតិ ។

៤.៤. ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ លើកទី២ ដើម្បីកែសម្រួល "ឯកសារបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ស្តីពី យុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព ក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន" ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ០២-០៧ ខែមីនា ឆ្នាំ២០១៤ ។

៤.៥. សហការសម្របសម្រួល និងជំរុញដំណើរការការងាររបស់គណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀន នៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ។

៤.៦. រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់នានា នៅតាមខ្សែបន្ទាត់ព្រំដែន ។

៤.៧. រៀបចំទីកន្លែងសម្រាប់ការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ដោយម៉ាស៊ីនកុំព្យូទ័រ (CBT) ។

៤.៨. បន្តការចូលរួមធ្វើបទឧទ្ទេសនាមអំពីសភាពការណ៍គ្រឿងញៀន និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់មន្ត្រីនគរបាលរបស់បណ្ឌិត្យសភាននគរបាលកម្ពុជា ។

៤.៩. បន្តជំរុញកិច្ចដំណើរការការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន នៅតាមបណ្តាខេត្តដែលមានការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

# ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

៥.១. ត្រៀមលក្ខណៈជូន ឯកឧត្តម អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីអញ្ជើញទៅចូលរួមក្នុងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន របស់អង្គការសហប្រជាជាតិ (CND) នៅទីក្រុងវីយែន ប្រទេសអូទ្រីស នៅថ្ងៃទី១៣-១៤/៣/២០១៤ ។

៥.២. ត្រៀមរៀបចំដំណើរទស្សកិច្ចរបស់ថ្នាក់ដឹកនាំ អ.ជ.ប.គ.ញ ទៅកាន់ប្រទេសវៀតណាម និង ប្រទេសឡាវ ។

៥.៣. បន្តទំនាក់ទំនងជាមួយស្ថានទូតចិន និងក្រសួងសន្តិសុខសាធារណៈចិន ពាក់ព័ន្ធនឹងដំណើរទស្សនកិច្ចរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អញ្ជើញទៅសាធារណរដ្ឋប្រជាមានិតចិន ។

ក្រៅពីទិសដៅការងារខាងលើ អគ្គលេខាធិការដ្ឋាននឹងបន្តអនុវត្តការងារមួយចំនួនទៀត ដើម្បីបំពេញឱ្យយុទ្ធសាស្ត្រជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានដូចជា :

- រៀបចំកិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិរបស់អាជ្ញាធរជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀនបន្ត ។
- ត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៣ និងទិសដៅការងារឆ្នាំ២០១៤ នៅថ្ងៃទី ២៥-២៦ ខែ មីនា ឆ្នាំ ២០១៤ ។

**អគ្គលេខាធិការ**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ

-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

**"ដើម្បីជូនជ្រាប"**

-ក្រសួង សមាជិក អ.ជ.ប.គ.ញ

-ក្រសួងផែនការ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត

-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

**"ដើម្បីមុខការ"**

-ឯកសារ